# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាជាមួយបូជាចារ្យទាំងអស់នៅភ្នំពេញ
# ថ្ងៃទី២៧ មិថុនា ២០១៧

| |
|---|
| អត្ថបទទី១៖កណ ១៣,២.៥-១៨ |
| ដំណឹងល្អ៖មថ ៧,៦.១២-១៤ |

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងគោរពសន្តប៉ូល និងសន្តសិលា ដែលជាអំណរសប្បាយសម្រាប់យើងទាំងអស់ ដោយសារក្នុងអាសនៈព្រះវិហារនេះយើងមានធាតុសន្តសិលា។ យូរៗម្តងយើងចូលនៅក្នុងព្រះវិហារភ្នំពេញថ្មីនេះ ដើម្បីគោរពសន្តសិលា។ សន្តប៉ូលកាន់ដាវយ៉ាងមុតដូចព្រះបន្ទូលត្រូវការណែនាំឲ្យភ្ញាក់ស្មារតីនៅក្នុងជីវិតរបស់យើង និងសន្តិសិលាកាន់សោរ ដើម្បីបើកទ្វារនៃស្ថានបរមសុខ ដើម្បីបើកទ្វារនៃជីវិត ដើម្បីស្រាយអំពើបាបរបស់យើងឲ្យយើងទទួលជីវិតថ្មីរួមជាមួយព្រះគ្រីស្ត។

ថ្ងៃនេះយើងជួបជុំគ្នាជាបូជាចារ្យទាំងអស់នៅក្នុងភូមិភាគភ្នំពេញ ជាតំណាងបុព្វជិតបុព្វជិតា ជាតំណាងបងប្អូនដែលទទួលខុសត្រូវតាមការិយាល័យរបស់ភូមិភាគភ្នំពេញទាំងអស់ ជាឱមួយដើម្បីអរព្រះគុណព្រះជាម្ចាស់ និងដើម្បីសម្លឹងមើលព្រះសហគមន៍ពីដើម។ ព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងភូមិភាគភ្នំពេញមានអាយុជាង៤៦០ឆ្នាំ ជាព្រះសហគមន៍ចាស់ម្យ៉ាង និងជាព្រះសហគមន៍ខ្ចីមែនទែន។ សព្វថ្ងៃយើងធ្វើការ និងរស់នៅជាមួយគ្រីស្តបរិស័ទជំនាន់ទីមួយយ៉ាងច្រើន ដូច្នេះពេលយើងនឹកឃើញជីវិតរបស់ព្រះសហគមន៍សកលដែលមានអាយុជាង២០០០ឆ្នាំ ប៉ុន្មានប្រទេសមានច្រើនជំនាន់មកហើយ។ ប៉ុន្តែព្រះសហគមន៍របស់យើង ដូចព្រះសហគមន៍នៅជំនាន់លោកសិលា លោកប៉ូល និងក្រុមគ្រីស្តទូតធ្លាប់ស្គាល់ពីដើម ដោយមានគ្រីស្តបរិស័ទថ្មីៗ មានបងប្អូនដែលកំពុងស្វែងយល់ព្រះបន្ទូល។ មានកន្លែងខ្លះដូចលោកប៉ូល លោកអាប៉ូឡូស លោកបាទីមេ លោកទីម៉ូថេ លោកសិលា ដែលបានទៅសាបព្រួសក្រោយមកមានរាប់ពាន់នាក់ដែលសុំដើរតាមព្រះយេស៊ូ។ យើងឥតមានរាប់ពាក់នាក់ តែយើងមានរាប់រយនាក់ជារៀងរាល់ឆ្នាំដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក និងកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ សព្វថ្ងៃនៅក្នុងភូមិភាគភ្នំពេញមាន៨០០នាក់ដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ក្នុងឆ្នាំនេះ ព្រះសហគមន៍កម្ពុជាទាំងមូលមានជាង៣០០នាក់ដែល

បានទទួលអគ្គសញ្ញាជ្រមុជទឹក។ ដូច្នេះបទពិសោធន៍របស់ព្រះសហគមន៍យើង ដូចបទពិសោធន៍របស់លោកប៉ូល លោកសិលា និងក្រុមគ្រីស្តទូតពីដើមដែលកំពុងបង្កើតព្រះសហគមន៍។ ពេលយើងមើលលោកសិលាគួរឲ្យស្រឡាញ់ ដោយសារជីវិតរបស់គាត់ធ្វើតាមព្រះយេស៊ូជានិច្ច ដូចយើងបានស្តាប់លោកសិលាឆ្លើយថា **"ពិតមែនលោកជាព្រះគ្រីស្ត លោកជាព្រះសង្គ្រោះ លោកជាព្រះបុត្រារបស់ព្រះជាម្ចាស់"** មានតែលោកសិលាដែលបង្ហាញជំនឿរបស់គាត់យ៉ាងខ្លាំងចំពោះព្រះជាម្ចាស់។ នៅថ្ងៃជប់លៀងចុងក្រោយ លោកសិលានៅតែប្រកាសថា ខ្ញុំនៅជាមួយព្រះអង្គ ហើយព្រះយេស៊ូថា **"ពេលមាន់រងាវអ្នកបានបដិសេធថាមិនស្គាល់ខ្ញុំបីដង"**។ ព្រះយេស៊ូបានជ្រើសរើសលោកសិលា ដែលមានចំនុចខ្សោយ ដែលមានអំពើបាប ដើម្បីធ្វើជាសិលាដ៏រឹងមាំ ជាគ្រឹះដ៏រឹងមាំរបស់ព្រះសហគមន៍។ លោកសិលា បានយកការលើកលែងទោសរបស់ព្រះយេស៊ូមកធ្វើជាបទពិសោធន៍ នៅពេលព្រះយេស៊ូសួរគាត់ថា **តើស្រឡាញ់ខ្ញុំទេឬ? តើស្រឡាញ់ខ្ញុំទេឬ? តើស្រឡាញ់ខ្ញុំទេឬ?** នៅពេលនោះព្រះយេស៊ូកំពុងលើកលែងទោសឲ្យលោកសិលា និងណែនាំឲ្យលោកសិលាទទួលខុសត្រូវព្រះសហគមន៍បន្តពីព្រះអង្គ។

ដូច្នេះ នៅពេលយើងមើលក្រុមគ្រីស្តទូតដែលជាមូលដ្ឋាននៃព្រះសហគមន៍ យើងនឹកឃើញជីវិតរបស់យើងជាបូជាចារ្យ ជាបុព្វជិតបុព្វជិតា ជាគ្រីស្តបរិស័ទ ជាបងប្អូនដែលបម្រើព្រះសហគមន៍ យើងដូចលោកសិលា ដែលមានកម្លាំងពេញខ្លួន ជួនកាលយើងភ្លេចខ្លួនដែរ តែយើងដឹងថាព្រះយេស៊ូបានលើកលែងទោសអោយយើង។ នៅពេលយើងធ្វើបទពិសោធន៍ អំពីការលើកលែងទោសរបស់ព្រះយេស៊ូនៅក្នុងជីវិតរបស់យើង ពិតមែនយើងមានសមត្ថភាពដើម្បីលើកលែងទោសឲ្យអ្នកដទៃតទៅទៀត។ ជាមូលហេតុដែលលោកសិលាមានសោរ ដើម្បីណែនាំឲ្យមនុស្សមួយចំនួនបានទទួលជីវិតថ្មីតាមរយៈព្រះហឫទ័យមេត្តាករុណា និងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។

លោកប៉ូលជាមនុស្សម្នាក់ដែលស្អប់គ្រីស្តបរិស័ទ ប៉ុន្តែក្រោយពេលដែលគាត់បានកែប្រែចិត្តគំនិតជីវិតរបស់គាត់បានស្ម័គ្រស្លាប់ដើម្បីព្រះយេស៊ូ។ អត្ថបទថ្ងៃនេះ ជាអត្ថបទមួយដែលជិតដល់ថ្ងៃចុងក្រោយនៃជីវិតរបស់គាត់ គាត់បានខិតខំ គាត់បានយកចិត្តទុកដាក់ដើម្បីណែនាំឲ្យមនុស្សជាច្រើនបានស្គាល់ព្រះយេស៊ូ។ នៅក្នុងជីវិតរបស់គាត់ដូចលោកសិលា គាត់បានធ្វើបទពិសោធន៍អំពីគារលើកលែងទោសរបស់ព្រះគ្រីស្ត ដើម្បីណែនាំឲ្យ

គាត់យល់អំពីព្រះសហគមន៍ដែលជាមាតាសម្រាប់យើង ព្រះសហគមន៍ដែលត្រូវតែលើកលែងទោសតាមរបៀបព្រះយេស៊ូដែលបានលើកលែងទោសឲ្យយើង។ លោកប៉ូលដែលបានបៀតបៀនគ្រីស្តបរិស័ទ ដែលបានសម្លាប់គេ ប៉ុន្តែនៅពេលព្រះយេស៊ូបានសួរគាត់ **"ស៊ូលអើយ! មូលហេតុអ្វីបៀតបៀនខ្ញុំ?"** នៅពេលនោះគាត់ភ្ញាក់និងបានទទួលជីវិតថ្មីដោយសារព្រះយេស៊ូមិនបានវិនិច្ឆ័យគាត់ ព្រះយេស៊ូមិនកាត់ក្តីគាត់ ប៉ុន្តែព្រះយេស៊ូបានជ្រើសរើសគាត់ឲ្យទទួលជីវិតថ្មី។ កែប្រែចិត្តគំនិតមានន័យណាស់ កែប្រែចិត្តគំនិតដើម្បីទៅជាគ្រីស្តទូតថ្មីមួយ ដោយចេញទៅប្រកាសដំណឹងល្អរហូតបូជាជីវិតសម្រាប់ព្រះយេស៊ូ ដែលគាត់បានស្រឡាញ់អស់ពីកម្លាំងកាយចិត្ត អស់ពីជំនឿរបស់គាត់។

នេះជាការអស្ចារ្យដើមដំបូងរបស់ព្រះសហគមន៍ ព្រះសហគមន៍បានកើតនៅពេលព្រះយេស៊ូចាប់ផ្តើមជ្រើសរើសក្រុមគ្រីស្តទូ១២រូប។ ក្រុមគ្រីស្តទូត១២រូបដែលព្រះយេស៊ូបានជ្រើសរើសនៅកន្លែងដែលគាត់ស្គាល់ យើងអាចនឹកឃើញព្រះសហគមន៍តូចមួយដែលកំពុងកើតឡើង ហើយបានរីកចម្រើននៅក្នុងពិភពលោកទាំងមូល។ ក្រុមគ្រីស្តទូតមានរបៀបខុសៗគ្នាដូចយើងទាំងអស់គ្នា យើងអាចទៅជាក្រុមគ្រីស្តទូតមួយដែលខិតខំតាមសមត្ថភាពរបស់គាត់។ លោកអេលីម៉ាថាយ ជាអ្នកទារពន្ធដែលពុករលួយ ប៉ុន្តែពេលព្រះយេស៊ូបានមើលភាពងងឹតនៃជីវិតរបស់គាត់ ព្រះយេស៊ូទៅជាពន្លឺមួយសម្រាប់គាត់ឲ្យគាត់បានទទួលជីវិតថ្មី និងបានចាប់ផ្តើមប្រកាសដំណឹងល្អតាមព្រះយេស៊ូដែរ។ លោកយ៉ាកុប និងលោកយ៉ូហាន គាត់គ្មានគំនិតអង្គុយនៅខាងស្តាំនៅខាងឆ្វេងព្រះយេស៊ូ ប៉ុន្តែដោយសារម្តាយគេដែលចង់ឲ្យកូនមានកន្លែងយ៉ាងល្អ។ ជួនកាលនៅក្នុងព្រះសហគមន៍របស់យើងមានគំនិតនេះដែល យើងចង់នៅកន្លែងល្អ ទោះបីមិនមែនយើង តែជាបងប្អូន ជាម្តាយយើងដែលមានគំនិតសម្រាប់យើង។ ប៉ុន្តែលោកទាំងពីរ បានបូជាជីវិតដើម្បីប្រកាសដំណឹងល្អ។ លោកថូម៉ាស មានការសង្ស័យច្រើន ដូចគ្នានឹងយើងប៉ុន្មានដងយើងមានការសង្ស័យនៅក្នុងជីវិតរបស់យើងដោយសារជំនឿរបស់យើងនៅស្ទើរ។ ព្រះយេស៊ូនិយាយថា **"អ្នកណាដែលមានជំនឿដោយឥតមើលឃើញ អ្នកនោះមានសុភមង្គលហើយ"** នេះជារបៀបដែលព្រះយេស៊ូណែនាំយើង។ នៅក្នុងជីវិតរបស់យើង ជំនឿរបស់យើងដែលបានទទួលអំណោយទានពីព្រះជាម្ចាស់ ជួនកាលយើងចូលនៅក្នុងភាពងងឹតខ្លះៗ ជួនកាលមានការសង្ស័យខ្លះៗ ជួនកាលយើងមានអារម្មណ៍ថាសប្បាយចិត្តជាមួយព្រះយេស៊ូ។ ពេលយើង

អានលិខិតរបស់អ្នកម្តាយតេរេសាបានសរសេរ យើងភ្ញាក់ដោយសារទំនាក់ទំនងរវាងគាត់នឹងព្រះជាម្ចាស់ពិបាកណាស់ អស់មួយជីវិតគាត់តែងតែមានសំនួរថា **តើព្រះជាម្ចាស់ស្រឡាញ់ខ្ញុំឬអត់?** គាត់បានគិតនៅក្នុងជីវិតរបស់គាត់។ ប៉ុន្តែដោយស្តាប់ និងដោយធ្វើជីវិតជារៀងរាល់ថ្ងៃ ឱព្រះអម្ចាស់អើយ! ខ្ញុំស្រឡាញ់ព្រះអង្គណាស់ និងខ្ញុំដឹងថាព្រះអង្គស្រឡាញ់ខ្ញុំយ៉ាងខ្លាំងដែរ។

លោកស៊ីម៉ូន ដែលជាអ្នកជាតិនិយម យើងមានច្រើនអ្នកជាតិនិយមនៅក្នុងព្រះសហគមន៍របស់យើង យើងដឹងថាយើងត្រូវតែស្រឡាញ់ប្រទេសជាតិ វប្បធម៌ ទំនៀមទំលាប់របស់យើង ប៉ុន្តែយើងឃើញព្រះយេស៊ូ បានទៅប្រកាសដំណឹងល្អនៅក្នុងពិភពលោកទាំងមូលតាមរយៈក្រុមគ្រីស្តទូតនីមួយៗ។ ព្រះយេស៊ូបានណែនាំឲ្យក្រុមគ្រីស្តទូតទៅក្នុងពិភពលោកទាំងមូល ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់យាងចូលតាមវប្បធម៌ តាមប្រពៃណី តាមរបៀបរបស់ប្រជាជននីមួយៗ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់កែប្រែប្រពៃណីរបស់យើង ឲ្យទៅជាប្រពៃណីថ្មីដោយទទួលពន្លឺពីព្រះជាម្ចាស់។ លោកស៊ីម៉ូនគាត់បានយល់ និងដើរតាមព្រះយេស៊ូ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះយេស៊ូទៅជាវប្បធម៌ថ្មីទៅជាកម្លាំងថ្មី ទៅជាជីវិតថ្មី ដែលណែនាំឲ្យយើងមានកម្លាំង។

មូលហេតុអ្វីនៅក្នុងក្រុមសាវ័កទាំង១២នាក់ ព្រះយេស៊ូស្រឡាញ់លោកយ៉ូហានជាងគេ ប៉ុន្តែពេលព្រះយេស៊ូចូលនៅក្នុងផ្នូរលោកយ៉ូហានមិនត្រូវការចូលទៅជាមួយទេ ពិតមែនគាត់យល់ហើយថាព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ មានគេច្រណែនលោកយ៉ូហានច្រើន ប៉ុន្តែចុងក្រោយបំផុតមានតែព្រះនាងម៉ារី និងលោកយ៉ូហានដែលនៅក្បែរឈើឆ្កាងរបស់ព្រះយេស៊ូ។ នៅពេលនោះលោកយ៉ូហាន ទៅជានិមិត្តរូបនៃព្រះសហគមន៍ថ្មីដែលកំពុងកើតឡើង លោកបានទទួលព្រះនាងម៉ារីជាមាតារបស់យើង និងមាតារបស់យើងបានទទួលលោកយ៉ូហានជានិមិត្តរូបនៃព្រះសហគមន៍ថ្មី ដែលមិនបានលះបង់ចោលនៅថ្ងៃចុងក្រោយរបស់ព្រះយេស៊ូដែលបានសោយទិវង្គត់នៅលើឈើឆ្កាង។ នេះជាជីវិតរបស់យើងនៅក្នុងព្រះសហគមន៍ យើងមានរបៀបខុសៗគ្នា ប៉ុន្តែយើងដឹងថាចុងក្រោយបំផុតយើងយកចិត្តទុកដាក់ដើម្បីបម្រើអស់ពីកម្លាំងកាយចិត្ត។

លោកយ៉ូដា ជាអាថិកំបាំងមួយ មូលហេតុអ្វីលោកយ៉ូដានៅក្នុងក្រុមគ្រីស្តទូត? ព្រោះគាត់ក្បត់ព្រះយេស៊ូ ក្រោយមកគាត់ចងករសម្លាប់ខ្លួន ដោយសារគាត់អស់សង្ឃឹម។ គាត់ធ្វើខុស ហើយសាវ័កផ្សេងទៀតក៏ធ្វើខុសដែរតែគេមិនបានសម្លាប់ខ្លួនដូចគាត់ទេ យើងមិនបានដឹងអំពីទំនាក់ទំនងរវាងលោកយ៉ូដា និងព្រះយេស៊ូនៅពេលនោះ តែយើងដឹងអំពីទំនាក់ទំនងរវាងលោកសិលានិងព្រះយេស៊ូ នៅពេលលោកសិលាបដិសេធបីដងថាមិនស្គាល់ព្រះអង្គនៅពេលនោះព្រះយេស៊ូឈរមើលគាត់ និងលោកសិលាឈរមើលព្រះយេស៊ូស្តាប់មាន់រងាវនិងគាត់យំ។ ប៉ុន្តែបងយើងឆ្ងល់ថា មូលហេតុអ្វីមានអំពើហិង្សារ? មូលហេតុអ្វីគេសម្លាប់អ្នកដទៃដែលគ្មានផលប្រយោជន៍សម្រាប់គេ? មូលហេតុអ្វីមានភារវរៈកម្ម? មូលហេតុអ្វីមានមនុស្សដែលសម្លាប់មនុស្ស? ជាមូលហេតុដែលយើងមានលោកយ៉ូដានៅក្នុងក្រុមគ្រីស្តទូតដែរ។ យើងមានសំនួរជាច្រើនដែលឆ្លើយមិនបាន ប៉ុន្តែយើងដឹងថាជីវិតរបស់យើងជាគ្រីស្តបរិសស័ទដែលបន្តជំនឿពីក្រុមគ្រីស្តទូត នៅក្នុងជីវិតដែលយើងបានទទួលពីព្រះជាម្ចាស់ ដោយសារព្រះសហាគមន៍ជាព្រះសហាគមន៍ដ៏វិសុទ្ធ ដោយសារជាព្រះសហាគមន៍របស់ព្រះជាម្ចាស់ដែលជាព្រះដ៏វិសុទ្ធ។

យើងជាក្រុមគ្រីស្តទូតទាំងអស់ ដែលកំពុងបន្តតួនាទីរបស់ព្រះយេស៊ូដែលណែនាំឲ្យយើងបង្កើតព្រះសហាគមន៍។ ប៉ុន្តែ យើងជាមនុស្សដែលមានបាប និងបានទទួលការសង្គ្រោះពីព្រហជាម្ចាស់តាមរយៈការលើកលែងទោស។ នេះជាសេចក្តីសង្ឃឹមសម្រាប់យើងជាគ្រីស្តបរិស័ទ ដែលណែនាំឲ្យយើងមានកម្លាំង ដើម្បីបន្តប្រកាសដំណឹងល្អ និងដើម្បីបន្តណែនាំព្រះបន្ទូលនៃការសង្គ្រោះអាចទៅគ្រប់ទីកន្លែង ជាពិសេសនៅព្រះសហាគមន៍របស់យើងក្នុងភូមិភាគភ្នំពេញ។ ខ្ញុំសូមអរគុណដល់ លោកបូជាចារ្យទាំងអស់ អរគុណដល់បងប្រុសបងស្រី បងប្អូនទាំងអស់ ដែលបានបម្រើព្រះសហាគមន៍ដើម្បីឲ្យព្រះសហាគមន៍របស់យើងរីកចម្រើនឡើង។ ថ្ងៃយើងគោរពសន្តសិលា និងសន្តប៉ូល អាចទៅជាព្រះសហាគមន៍របស់ព្រះគ្រីស្ត ដែលយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ មានន័យថាណែនាំឲ្យជីវិត ណែនាំឲ្យសេចក្តីស្រឡាញ់ ណែនាំឲ្យការលើកលែងទោស ដែលមកពីព្រះជាម្ចាស់អាចកើតឡើងនៅគ្រប់ទីកន្លែងដែលយើងនៅ និងនៅគ្រប់ទីកន្លែងដែលយើងមិនទាន់នៅ។ អាម៉ែន៕